

# អនុសញ្ញាលេខ ១៩០ របស់អង្គការ ILO
## ស្តីពីអំពើហិង្សា និងការបៀតបៀន ក្នុងពិភពការងារ

## តោះយើងរៀបចំយុទ្ធនាការធ្វើឱ្យមានការផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៩០

ក្នុងនាមជាសហជីព យើងមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឲ្យមានការប្រែក្លាយពីអនុសញ្ញានេះទៅជាការអនុវត្តជាក់ស្តែង។

យើងត្រូវសហការជាមួយគ្នា ធ្វើយ៉ាងណាឲ្យរដ្ឋជាសមាជិកផ្តល់សច្ចាប័នលើអនុសញ្ញានេះ និងធ្វើឲ្យអនុសញ្ញានេះ ជាផ្នែកមួយនៃច្បាប់ជាតិ។

### អ្វីសហជីពអាចធ្វើអ្វីបានខ្លះ ៖

- បង្កើនការយល់ដឹង និងផ្តល់ការអប់រំសមាជិកសហជីព និងសង្គមទាំងមូល។
- ធ្វើយុទ្ធនាការយ៉ាងសកម្ម ដើម្បីឲ្យមានការផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៩០ នៅតាមប្រទេសនីមួយៗ។
- ប្រមូលផ្តុំកម្មករលើបញ្ហាអំពើហិង្សា និងការបៀតបៀនក្នុងពិភពការងារ។
- បង្កើតសម្ព័ន្ធភាពជាមួយសហជីព សហភាព អង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ ជាពិសេស ក្រុមសិទ្ធិស្ត្រី ដើម្បីជួយលុបបំបាត់អំពើហិង្សា និងការបៀតបៀននៅកន្លែងការងារ។
- បង្កើតរចនាសម្ព័ន្ធសម្រាប់តស៊ូមតិឲ្យមានការផ្តល់សច្ចាប័ន។

**អ្នកអាចរកបានឯកសារយុទ្ធនាការបន្ថែមទៀត តាមរយៈ៖**

**សហជីពសកល** UNI www.breakingthecircle.org

PSI www.publicservices.international/campaigns/stop-gender-based-violence-at-work?id=5676&lang=en

IUF www.iuf.org/show.php?lang=en&tid=82

IDWF www.idwfed.org/en/campaigns/c190

INDUSTRIALL www.industriall-union.org/women-0

IFJ www.ifj.org/what/gender-equality.html

## អនុសញ្ញានេះ អាចកែប្រែជីវិតបាន

**អំពើហិង្សា និងការបៀតបៀនក្នុងពិភពការងារ អាចកើតឡើងនៅគ្រប់ទីកន្លែង** គឺ អនឡាញ នៅកន្លែងធ្វើការ ក្នុងពេលធ្វើដំណើរទៅមក កន្លែងកម្មករសម្រាក បរិភោគអាហារ ឬកន្លែងទទួលសេវាសុខភាព និងអនាម័យ របស់ពួកគេ រួមទាំងកន្លែងជួបជុំក្នុងសង្គមផងដែរ ។

## យើងអាចបញ្ឈប់វាបាន!

នៅខែមិថុនា ឆ្នាំ ២០១៩ សន្និសីទការងារ អន្តរជាតិ លើកឡើងថា ត្រូវបញ្ឈប់អំពើហិង្សា និងការបៀតបៀនក្នុងពិភពការងារ ដោយបានបង្កើតឧបករណ៍អន្តរជាតិថ្មីមួយ គឺ អនុសញ្ញាលេខ ១៩០ (C190) និង អនុសាសន៍លេខ ២០៦ (R206)។

អនុសញ្ញាថ្មីនេះ ការពារកម្មករគ្រប់រូប ដោយមិនគិតពីស្ថានភាពកិច្ចសន្យាការងាររបស់ពួកគេ ជាអ្នកធ្វើកម្មសិក្សា ហ្វឹកហាត់ការងារ បណ្តុះបណ្តាល កម្មករដែលបានបញ្ឈប់ពីការងារ អ្នកស្ម័គ្រចិត្ត និងអ្នកស្វែងរកការងារធ្វើ ។

- អនុសញ្ញានេះ ផ្តោតសំខាន់លើអំពើហិង្សាដោយសារយេនឌ័រ។ ស្ត្រីទទួលរងផលប៉ះពាល់ខ្លាំងជាង ដោយសារតែអំពើហិង្សា និងការបៀតបៀនក្នុងពិភពការងារ។
- អនុសញ្ញានេះ គ្រប់ដណ្តប់លើវិស័យទាំងអស់ ទាំងវិស័យឯកជន និងសាធារណៈ ជនបទ និងទីប្រជុំជន សេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។
- អនុសញ្ញានេះ កត់សម្គាល់ថា មនុស្សគ្រប់រូបមានសិទ្ធិរួចផុតពីអំពើហិង្សា និងការបៀតបៀនក្នុងពិភពលោកការងារ។
- អនុសញ្ញានេះ នឹងបំពេញចំណុចខ្វះខាត ដែលមាននៅក្នុងបទប្បញ្ញត្តិជាតិ។

### ហេតុអ្វីអនុសញ្ញាលេខ ១៩០ មានសារៈសំខាន់?

- អំពើហិង្សា និងការបៀតបៀនក្នុងពិភពការងារ ជាអំពើដែលមិនអាចអត់អោនឲ្យបាន។
- នេះគឺជាស្តង់ដារអន្តរជាតិដំបូងគេដែលផ្តោតលើការបញ្ឈប់អំពើហិង្សា និងការបៀតបៀនក្នុងពិភពការងារ។
- អនុសញ្ញានេះ កត់សម្គាល់ថា មនុស្សគ្រប់រូបមានសិទ្ធិរួចផុតពីអំពើហិង្សា និងការបៀតបៀនក្នុងពិភពការងារ។
- អនុសញ្ញានេះ នឹងបំពេញចំណុចខ្វះខាត ដែលមាននៅក្នុងបទប្បញ្ញត្តិជាតិ។

# ការផ្លាស់ប្តូរឥរិយាបថ និងការលើកកម្ពស់សមភាពយេនឌ័រ

**យើងទាំងអស់គ្នាក្នុងពិភពការងារ (រដ្ឋាភិបាល និយោជក និងកម្មករ) សុទ្ធតែមានតួនាទីក្នុងការផ្តល់ និងធានានូវវប្បធម៌ការងារមួយដែលផ្តោតលើការគោរពគ្នាទៅវិញទៅមក និងសេចក្តីថ្លៃថ្នូរ។**

- អនុសញ្ញានេះ គឺជាឧបករណ៍ដ៏សំខាន់សម្រាប់ប្រយុទ្ធប្រឆាំងនឹងការរើសអើង និងវិសមភាពក្នុងពិភពការងារ។
- អនុសញ្ញានេះ ចែងថា រដ្ឋាភិបាលត្រូវអនុម័ត **បទប្បញ្ញត្តិដែលធានានូវសិទ្ធិទទួលបានសមភាព និងគ្មានការរើសអើងក្នុងការងារ និងមុខរបរ សម្រាប់មនុស្ស គ្រប់រូប រួមទាំងស្ត្រី ជនចំណាកស្រុក ជនពិការ និង អ្នកដែលមានអត្តសញ្ញាណចម្រុះ** និងពាក់ព័ន្ធគ្នា មិនថា ជាតិសាសន៍ ជាតិពិន្ទុ ជាជនជាតិដើមភាគតិច និន្នាការផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រឡើយ។
- ការវាយតម្លៃហានិភ័យនៅកន្លែងធ្វើការ ដែលមានចែងក្នុងអនុសញ្ញានេះ អាចជួយផ្លាស់ប្តូរឥរិយាបថ ព្រោះការវាយតម្លៃទាំងនោះ អាចពិចារណាលើកត្តាផ្សេងៗ ដែលបង្កើនលទ្ធភាពកើតមានអំពើហិង្សា ដោយសារយេនឌ័រ និងការបៀតបៀន (ដូចជា បទដ្ឋានយេនឌ័រ បទដ្ឋានវប្បធម៌ និងសង្គម)។
- អនុសញ្ញាលេខ ១៩០ បញ្ចូលជាលើកដំបូងនូវ **អំពើហិង្សាក្នុងគ្រួសារថាជាផ្នែកមួយដែលប៉ះពាល់ដល់ការងារ និង**សុខភាព និងសុវត្ថិភាពរបស់កម្មករ។

## តើអ្វីជាអំពើហិង្សា និងការបៀតបៀន?

- អំពើហិង្សា និងការបៀតបៀន គឺជាឥរិយាបថ និងការអនុវត្តដែលមិនអាចទទួលយកបាន ឬជាការគំរាមកំហែងដែលអាចកើតឡើងម្តង ឬច្រើនដង ក្នុងគោលបំណងដើម្បី ឬធ្វើឲ្យមាន ឬអាចធ្វើឲ្យមានព្យសនកម្មផ្លូវកាយ ផ្លូវចិត្ត ឬសេដ្ឋកិច្ច។
- អំពើហិង្សា និងការបៀតបៀន លើសពីការរំលោភបំពានរាង្គកាយ និងអាចមានទម្រង់ជាការបៀតបៀនផ្លូវភេទ ការរំលោភបំពានពាក្យសម្តី និងផ្លូវចិត្ត ការរករឿងរំខាន ការវាយប្រហារ ការគំរាមកំហែង និងការឈ្លបចាប់។ ការបដិសេធការផ្តល់ធនធាន ឬលទ្ធភាពទទួលបានសេវា និងការដកហូតសេរីភាពផ្សេងទៀត ក៏ជាទម្រង់នៃអំពើហិង្សាដែរ។
- ជនបង្កអាចជានិយោជក អ្នកគ្រប់គ្រង ប្រធានត្រួតពិនិត្យ មិត្តភក្តិ សហការី រួមទាំង តតីយជន ដូចជា អតិថិជន សាច់ញាតិ ឬមិត្តភក្តិរបស់និយោជក និងអ្នកផ្តល់សេវា។
- **អំពើហិង្សាបង្កផលប៉ះពាល់ទាំងចំពោះបុរសនិងស្ត្រី ប៉ុន្តែស្ត្រីរងផលប៉ះពាល់ខ្លាំងជាងបុរស។**
- អំពើហិង្សាដោយសារយេនឌ័រ ជាអំពើហិង្សាដែលសំដៅលើមនុស្សណាម្នាក់ ដោយសារតែភេទ ឬយេនឌ័ររបស់ពួកគេ។
- ដោយមិនគិតពីស្ថានភាពសេដ្ឋកិច្ច ស្ត្រី និងក្មេងស្រីម្នាក់ក្នុងចំនោមស្ត្រី និងក្មេងស្រីបីនាក់ជួបប្រទះអំពើហិង្សាក្នុងជីវិតរបស់ពួកគេ។

# អនុសញ្ញាលេខ ១៩០ និងសហជីព នេះជាឧបករណ៍របស់យើង ហើយយើងគួរប្រើប្រាស់វា

**ក្នុងអនុសញ្ញាលេខ ១៩០ ៖**

- អំពើហិង្សាដោយសារយេនឌ័រ និងការបៀតបៀន រួមទាំងអំពើហិង្សាគ្រួសារ គួរត្រូវបានបញ្ជ្រាបទៅក្នុងសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការ ។
- និយោជកត្រូវចាត់វិធានការ និងបង្កើតគោលនយោបាយនៅកន្លែងធ្វើការ ដោយពិគ្រោះយោបល់ ជាមួយសហជីត ដើម្បីទប់ស្កាត់អំពើហិង្សា និងការបៀតប្រៀន។
- រដ្ឋមានកាតព្វកិច្ចផ្តល់ធនធាន និងការបណ្តុះបណ្តាលពីអំពើហិង្សា និងការប្រៀតប្រៀនក្នុងពិភពការងាររួមទាំង អំពើហិង្សាដោយសារយេនឌ័រ ដល់សហជីព។

អនុសញ្ញាលេខ ១៩០ នឹងចូលជាធរមានក្នុងរយៈពេល ១២ ខែ បន្ទាប់ពីរដ្ឋជាសមាជិកពីរបស់អង្គការ ILO ផ្តល់សច្ចាប័នអនុសញ្ញានេះ ប៉ុន្តែសហជីពមិនចាំបាច់រង់ចាំការផ្តល់សច្ចាប័នទេ។ យើងគួរប្រើប្រាស់លិខិតុបករណ៍នេះ ឲ្យបានឆាប់ដើម្បីផ្លាស់ប្តូរជីវិតរស់នៅរបស់កម្មករនិយោជិត។

**អនុសញ្ញាលេខ ១៩០ របស់អង្គការ ILO**

**ក្នុងអនុសញ្ញាលេខ ១៩០ ផ្តល់ការជំរុញដល់សហជីព និងអ្នកពាក់ព័ន្ធផ្សេងទៀត ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សា និងការប្រៀតប្រៀនក្នុងពិភពការងារ។**

**តោះយើងប្រើប្រាស់អនុសញ្ញាលេខ ១៩០ នៅពេលនេះតែម្តង!**

- លើកកម្ពស់ការមិនរើសអើង និងសមភាពតាមរយៈយុទ្ធនាការ និងការចរចាជាសមូហភាព។
- អប់រំសមាជិកសហជីពពីអ្វីជាអំពើហិង្សា និងការបៀតបៀនក្នុងពិភពការងារ។
- បង្កើនការយល់ដឹងរបស់សមាជិកសហជីពអំពីអនុសញ្ញាលេខ ១៩០ និងសារៈសំខាន់របស់វា។ អនុសញ្ញានេះ គឺជាអនុសញ្ញាដែលអាចកែប្រែជីវិត ដែលជួយដល់កម្មកររាប់លាននាក់ឲ្យទទួលបានបរិយាកាសការងារដែលមានសុវត្ថិភាព ជួយលុបបំបាត់អំពើហិង្សា និងការបៀតបៀនគ្រប់ទម្រង់ ជាពិសេស អំពើហិង្សាដោយសារយេនឌ័រ។
- បញ្ចូលខ្លឹមសារនៃលិខិតុបករណ៍ទាំងនេះ (C190/R206) ទៅក្នុងអនុសញ្ញារួម។
- សហការជាមួយនិយោជកដើម្បីធ្វើយ៉ាងណាឲ្យគោលនយោបាយសុខភាព និងសុវត្ថិភាព ដោះស្រាយអំពើហិង្សា និងការបៀតបៀន និងជាពិសេស អំពើហិង្សាដោយសារយេនឌ័រ។
- គាំទ្រដល់ការងាររបស់សហព័ន្ធសហជីពសកល ក្នុងការចរចាបង្កើតកិច្ចព្រមព្រៀងក្របខ័ណ្ឌសកលដោយដាក់បញ្ចូលខ្លឹមសារនៃលិខិតុបករណ៍ទាំងនេះ (C190/R206) ដើម្បីប្រយុទ្ធប្រឆាំងអំពើហិង្សា និងការបៀតបៀនក្នុងពិភពលោក។